ប្រការ ៤ : គណៈកម្មការនេះមានសិទ្ធិប្រើប្រាស់ត្រាក្រសួងរៀបចំដែនដី នគរូបនីយកម្ម និងសំណង់ សំរាប់សំរួលការងារ ។

ប្រការ ៥ : សមាជិកគណៈកម្មការត្រូវចូលរួមតាមសេចក្ដីអញ្ជើញរបស់ប្រធាន ។

មាត្រា ៦ : រដ្ឋមន្ត្រីទទួលបន្ទុកទីស្ដីការគណៈរដ្ឋមន្ត្រី រដ្ឋមន្ត្រីក្រសួងរៀបចំដែនដី នគរូបនីយកម្ម និងសំណង់ រដ្ឋមន្ត្រីក្រសួងកសិកម្ម រុក្ខាប្រមាញ់និងនេសាទ សហរដ្ឋមន្ត្រីមហាផ្ទៃ សហរដ្ឋមន្ត្រីក្រសួងការពារជាតិ រដ្ឋមន្ត្រី រដ្ឋលេខាធិការ នៃក្រសួង ស្ថាប័ន-ពាក់ព័ន្ធ និងឯកឧត្តមអស់លោក ដែលមានឈ្មោះក្នុងប្រការ ១ និងប្រការ២ ត្រូវទទួលអនុវត្តសេចក្ដីសំរេចអោយមានប្រសិទ្ធភាព ចាប់ពីថ្ងៃចុះហត្ថលេខាតទៅ ។

នាយករដ្ឋមន្ត្រី

ហត្ថលេខា និងត្រា

ហ៊ុន សែន

***

រាជធានីភ្នំពេញ, ថ្ងៃទី០៧ ខែមេសា ឆ្នាំ២០០០

**សេចក្ដីសំរេចលេខ ២៥ សសរ.**

**ស្ដីពីការបង្កើតគណៈកម្មការអន្តរក្រសួង**

**សំរាប់ការងារស្ដារ និងបូមដីតាមដងទន្លេ**

***

**រាជរដ្ឋាភិបាល**

- បានឃើញរដ្ឋធម្មនុញ្ញនៃព្រះរាជាណាចក្រកម្ពុជា
- បានឃើញព្រះរាជក្រឹត្យលេខ នស/រកត/១១៩៨/៧២ ចុះថ្ងៃទី៣០ ខែវិច្ឆិកា ឆ្នាំ ១៩៩៨ ស្ដីពីការតែង តាំងរាជរដ្ឋាភិបាល នៃព្រះរាជាណាចក្រកម្ពុជា
- បានឃើញព្រះរាជក្រមលេខ ០២/នស/៩៤ ចុះថ្ងៃទី២០ ខែកក្កដា ឆ្នាំ១៩៩៤ ដែលប្រកាសអោយប្រើ ច្បាប់ ស្ដីពីការរៀបចំ និងការប្រព្រឹត្តទៅនៃគណៈរដ្ឋមន្ត្រី
- យោងតាមសំណូមពរការងារចាំបាច់របស់រាជរដ្ឋាភិបាល

**សំរេច**

ប្រការ ១ : បង្កើតគណៈកម្មការអន្តរក្រសួងសំរាប់ការងារស្ដារ និងបូមដីតាមដងទន្លេ ដែលមានសមាសភាពដូចខាងក្រោម :

១- រដ្ឋមន្ត្រីក្រសួងធនធានទឹក និងឧតុនិយម ប្រធាន

២- រដ្ឋមន្ត្រីក្រសួងរៀបចំដែនដីនគរូបនីយកម្មនិងសំណង់ សមាជិក

៣- រដ្ឋមន្ត្រីក្រសួងសាធារណការនិងដឹកជញ្ជូន សមាជិក

៤- រដ្ឋមន្ត្រីក្រសួងកសិកម្មរុក្ខាប្រមាញ់ និងនេសាទ សមាជិក

៥- តំណាងអាជ្ញាធរដែនដីគ្រប់ខេត្ត-ក្រុង ដែលពាក់ព័ន្ធ សមាជិក

៦- តំណាងគណៈកម្មាធិការជាតិទន្លេមេគង្គកម្ពុជា សមាជិក

៧- អគ្គនាយកកិច្ចការបច្ចេកទេស នៃក្រសួងធនធានទឹកនិងឧតុនិយម សមាជិក

**ប្រការ ២ :** គណៈកម្មការអន្តរក្រសួងនេះមានភារកិច្ច :

១- ធ្វើការសិក្សា ពិនិត្យ ពិចារណា និងលើកសំណើជូនរាជរដ្ឋាភិបាល ដើម្បីពិនិត្យសំរេចរាល់បញ្ហាដែលពាក់ ព័ន្ធនឹងការងារស្តារ និងបូមដីតាមដងទន្លេ ។

២- រួមសហការណែនាំបណ្តាផ្នែក នៃក្រសួងពាក់ព័ន្ធ ដើម្បីអនុវត្តសេចក្តីសំរេចទាំងឡាយរបស់រាជរដ្ឋាភិបាល ស្តីពីការងារស្តារ និងបូមដីតាមដងទន្លេ ។

៣- ពង្រឹងសហប្រតិបត្តិការជាមួយបណ្តាប្រទេសផ្តល់ជំនួយ និងអង្គការអន្តរជាតិនានា ក្នុងការពិភាក្សានិង ពិចារណា ការសិក្សា និងអភិវឌ្ឍន៍ការងារស្តារទន្លេក្នុងព្រះរាជាណាចក្រកម្ពុជា ។

៤- ធ្វើទំនាក់ទំនងសំរបសំរួលជាមួយបណ្តាសហគមន៍ផ្តល់ជំនួយអន្តរជាតិ ដើម្បីស្វែងរកទុនជំរុញការសិក្សា និងអភិវឌ្ឍន៍គំរោងអោយបានទាន់ពេលវេលា និងមានប្រសិទ្ធភាពខ្ពស់ ។

**ប្រការ ៣ :** គណៈកម្មការអន្តរក្រសួងនេះ មានសិទ្ធិបង្កើតអនុគណៈកម្មការមួយចំនួន តាមការចាំបាច់ ដើម្បីជំនួយការ ។

**ប្រការ ៤ :** គណៈក ម្មការអន្តរក្រសួងនេះ មានទីតាំងស្ថិតនៅទីស្តីការក្រសួងធនធានទឹក និងឧតុនិយម ហើយមានសិទ្ធិប្រើប្រាស់ត្រាជាផ្លូវការរបស់ក្រសួងធនធានទឹក និងឧតុនិយម ។

**ប្រការ ៥ :** សមាជិកគណៈក ម្មការទាំងអស់ត្រូវចូលរួមប្រជុំតាមការអញ្ជើញរបស់ប្រធាន ។

**ប្រការ៦ :** បទបញ្ញត្តិទាំងឡាយណាដែលផ្ទុយនឹងសេចក្តីសំរេចនេះ ត្រូវទុកជានិរាករណ៍ ។

**ប្រការ៧ :** រដ្ឋមន្ត្រីទទួលបន្ទុកទីស្តីការគណៈរដ្ឋមន្ត្រី រដ្ឋមន្ត្រីក្រសួងធនធានទឹក និងឧតុនិយម រដ្ឋមន្ត្រី និងរដ្ឋលេខាធិការនៃក្រសួងស្ថាប័ន និងអាជ្ញាធរដែនដី ខេត្ត-ក្រុង ដែលពាក់ព័ន្ធ ត្រូវអនុវត្តន៍នូវសេចក្តីសំរេចនេះ អោយមាន ប្រសិទ្ធភាពចាប់ពីថ្ងៃចុះហត្ថលេខាតទៅ ។

នាយករដ្ឋមន្ត្រី

ហត្ថលេខា និងត្រា

**ហ៊ុន សែន**

★★★